គ្រ. អាមែន ។

ប. សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ
ប្រទានព្រះពរដល់អស់បងប្អូន
គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

គ្រ. អាមែន ។



# ពិធីអគ្គសញ្ញាលាបប្រេងអ្នកជំងឺ និងពិធីទទួលព្រះកាយព្រះគ្រីស្ត

## ១ - ពិធីទទួលភ្ញៀវ

ប. **ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។**

គ្រ. អាម៉ែន ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមឲ្យអស់អ្នកដែលនៅផ្ទះនេះបានប្រកបដោយសេចក្តីសុខសាន្ត ។

## ២ - ពិធីបាចទឹក

ប. បពិត្រព្រះជាម្ចាស់!
ព្រះអង្គប្រើអគ្គសញ្ញាផ្សេងៗ
ដើម្បីបង្ហាញការអស្ចារ្យនៃឫទ្ធានុភាពរបស់ព្រះអង្គ ហើយទ្រង់ប្រើទឹក
ជានិមិត្តរូបនៃការសង្គ្រោះមនុស្សលោកតាំងពីដើមរៀងមក ។
បពិត្រព្រះអម្ចាស់ជាព្រះបិតា!
សូមប្រោសឲ្យព្រះវិញ្ញាណដ៏មានឫទ្ធានុភាព យាងមកគង់លើទឹកនេះ ។
សូមព្រះអង្គលាងជម្រះយើងខ្ញុំជាថ្មី
ដើម្បីឲ្យយើងខ្ញុំភ្ជាប់ចិត្តជាមួយព្រះយេស៊ូគ្រីស្ត កាន់តែខ្លាំងឡើងៗ ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់ ដែលសោយរាជ្យរួមជាមួយព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ ។

គ្រ. អាម៉ែន ។

លោកបូជាចារ្យអាចយកទឹកមកបាចលើអ្នកជំងឺនិងលើគ្រីស្តបរិស័ទឯទៀតទាំងមានប្រសាសន៍ថា៖

ប. ទឹកនេះនាំឲ្យយើងនឹកដល់ពេលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ព្រមទាំងនាំឲ្យយើងនឹកថា មានតែព្រះគ្រីស្តមួយព្រះអង្គទេ ដែលសង្គ្រោះមនុស្សលោកដោយទ្រង់សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ។

បាចទឹករួចហើយ លោកអធិដ្ឋានដូចតទៅ៖

ប. ឱ! ព្រះយេស៊ូជាអម្ចាស់ ព្រះអង្គមានព្រះបន្ទូលតាមរយៈ គ្រីស្តទូតយ៉ាកុបថា៖ « ប្រសិនបើមានបងប្អូនណាម្នាក់មានជំងឺ ចូរបងប្អូនអញ្ជើញចាស់ទុំនៃព្រះសហគមន៍មក ។ ចាស់ទុំ និងលាបប្រេងឲ្យគាត់ ក្នុងព្រះនាមរបស់ព្រះអង្គ ព្រមទាំងអង្វរព្រះអម្ចាស់ឲ្យគាត់ផង ។ ពាក្យអង្វរដែលហូរចេញមកពីជំនឿនឹងសង្គ្រោះអ្នកជំងឺនោះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឲ្យបានជា ។ ប្រសិនបើគេបានប្រព្រឹត្តអំពើបាបពីមុនៗមក ព្រះអង្គនឹងលើកលែងទោសឲ្យគេ » ។

លោកបូជាចារ្យលាតដៃប្រទានពរលើអ្នកជំងឺ៖

ប. យើងខ្ញុំសូមចូលរួមនៅជីនេះ ក្នុងព្រះនាមព្រះអង្គ ។ សូមទ្រង់ព្រះមេត្តាអាណិតអាសូរបងប្អូនយើងខ្ញុំ ដែលមានជំងឺ (ដែលចាស់ជរាទៅហើយ - ដែលគេហៀបនឹងវះកាត់) នេះ ។



# ៧ - ពាក្យអររព្រះគុណព្រះជាម្ចាស់

ប. សូមបងប្អូនតាំងចិត្តអធិដ្ឋាន ។

ប. បពិត្រព្រះបិតា ដែលគង់នៅអស់កល្បជានិច្ច
ដែលមានឫទ្ធានុភាពសព្វប្រការ យើងខ្ញុំសូមអង្វរព្រះអង្គដោយទទូច
សូមព្រះមេត្តាថែរក្សាបងប្អូនយើងខ្ញុំ (ឈ្មោះ....)
សូមឲ្យព្រះកាយនិងព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ត
ប្រែទៅជាឱសថដ៏វិសុទ្ធដែលផ្តល់ជីវិតអស់កល្បជានិច្ច
សម្រាប់រូបកាយ និងព្រលឹងវិញ្ញាណរបស់គាត់
ដោយរួមជាមួយព្រះយេស៊ូ ដែលសោយរាជ្យជាមួយព្រះអង្គ
និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែងតរៀងទៅ ។

គ្រ. អាមែន ។

លោកបូជាចារ្យបញ្ចប់ពិធីនេះ ទាំងមានប្រសាសន៍ថា៖

ប. សូមព្រះបិតាជាអម្ចាស់ប្រទានពរឲ្យអស់បងប្អូន
តាមធម៌មេត្តាករុណារបស់ព្រះអង្គ ។

គ្រ. អាមែន ។

ប. សូមព្រះយេស៊ូគ្រីស្តជាព្រះបុត្រាលើកទឹកចិត្តបងប្អូន ។

គ្រ. អាមែន ។

ប. សូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតបងប្អូន ។

**ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព**

**និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ។**

ប. សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់ គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. នេះជាកូនចៀមរបស់ព្រះជាម្ចាស់
នេះជាព្រះអង្គដែលដកបាបនៃពិភពលោក ។
អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម
អ្នកនោះពិតជាមានសុភមង្គលហើយ ។

លោកបូជាចារ្យ រួមជាមួយអង្គប្រជុំ ពោលបន្តថា ៖

ឱ ព្រះអម្ចាស់អើយ !

ខ្ញុំមិនសមនឹងទទួលព្រះអង្គក្នុងផ្ទះខ្ញុំទេ

តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក

នោះព្រលឹងខ្ញុំនឹងជាសះស្បើយ ។

ប. ព្រះកាយព្រះគ្រីស្ត ។

គ្រ. អាម៉ែន ។



សូមឲ្យគាត់មានជំនឿយ៉ាងមាំមួន និងមានចិត្តក្លាហានផង ។
យើងខ្ញុំសូមអង្វរព្រះអង្គ ដែលមានព្រះជន្មគង់នៅអស់កាលជាអង្វែងត
រៀងទៅ ។ គ្រ. អាម៉ែន ។

លោកបូជាចារ្យអញ្ជើញអង្គប្រជុំឲ្យទទួលសារភាព ៖

ប. សូមបងប្អូនទទួលសារភាពថា យើងជាអ្នកមានបាប សូមព្រះអម្ចាស់
រំដោះ បាបឲ្យយើង ដើម្បីអោយយើងអធិដ្ឋានដោយសមរម្យ ។

អង្គប្រជុំស្ងៀមស្ងាត់បន្តិច ហើយសូត្រធម៌សូមទទួលសារភាពរួមជាមួយគ្នា

គ្រ. ខ្ញុំសូមទទួលសារភាព ចំពោះព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ហើយចំពោះអស់បងប្អូនផងថា ខ្ញុំបានប្រព្រឹត្តអំពើបាបច្រើន
ដោយកាយវាចាចិត្ត និងដោយខានបំពេញកិច្ចការរបស់ខ្ញុំ
(គក់ទ្រូង) ទោសខ្ញុំអើយ ទោសខ្ញុំអើយ ទោសខ្ញុំអើយធ្ងន់ណាស់ ។
ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី អស់ទេវទូត និងសន្តបុគ្គល
ទាំងឡាយព្រមទាំងអស់បងប្អូន សូមជួយអង្វរព្រះជាអម្ចាស់ឲ្យខ្ញុំផង ។

លោកបូជាចារ្យ សូមព្រះជាម្ចាស់លើកលែងទោសឲ្យអង្គប្រជុំ ៖

ប. សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ
ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំ រួចពីបាប
ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ចឲ្យយើងខ្ញុំ ។ គ្រ.៖ អាម៉ែន ។

គ្រ ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ (អង្គប្រជុំឆ្លើយបន្ទរ)
ឱ ព្រះគ្រីស្តអើយ ! សូមអាណិតអាសូរ (អង្គប្រជុំឆ្លើយបន្ទរ)
ឱ ព្រះអម្ចាស់អើយ ! សូមអាណិតអាសូរ (អង្គប្រជុំឆ្លើយបន្ទរ)

# ៣ - ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

## ១យហ ២,២៨-៣,៦

### សូមថ្លែងលិខិតទី១ របស់សន្ត យ៉ូហាន

[២៨]ឥឡូវនេះ កូនចៅទាំងឡាយអើយ ចូរស្ថិតនៅជាប់នឹងព្រះយេស៊ូចុះ ដើម្បីអោយ
យើងមានចិត្តរឹងប៉ឹង នៅថ្ងៃដែលព្រះអង្គយាងមកយ៉ាងរុងរឿង ហើយពេលព្រះអង្គ
យាងមកនោះ យើងនឹងមិនត្រូវអៀនខ្មាសនៅចំពោះព្រះភក្ត្រព្រះអង្គឡើយ ។ [២៩]អ្នក
រាល់គ្នាដឹង ស្រាប់ហើយថា ព្រះអង្គសុចរិត ហេតុនេះ ចូរអ្នករាល់គ្នាដឹងដែរថា អស់
អ្នកដែលប្រព្រឹត្តតាមសេចក្ដីសុចរិត សុទ្ធតែកើតមកពីព្រះអង្គទាំងអស់ ។

[១]សូមគិតមើល៍ ព្រះបិតាមានព្រះហឫទ័យស្រឡាញ់យើងខ្លាំងដល់កំរិតណា គឺព្រះអង្គ
ស្រឡាញ់យើង រហូតដល់ទៅហៅយើងថា ជាបុត្រធីតារបស់ព្រះអង្គ ហើយយើងពិត
ជាបុត្រធីតារបស់ព្រះអង្គមែន! ហេតុនេះហើយបានជាមនុស្សលោកមិនស្គាល់យើង
មកពីគេមិនបានស្គាល់ព្រះអង្គ ។ [២]កូនចៅជាទីស្រឡាញ់អើយ! ពេលនេះ យើងទាំង
អស់គ្នាជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយដែលយើងនឹងទៅជាយ៉ាងណាៗនោះព្រះ
អង្គពុំទាន់សំដែងអោយយើងដឹង នៅឡើយទេ ។ ប៉ុន្តែ នៅពេលព្រះគ្រីស្តយាងមក
ដល់ យើងនឹងបានដូចព្រះអង្គដែរ ដ្បិតព្រះអង្គមានភាពយ៉ាងណា យើងនឹងឃើញព្រះ
អង្គយ៉ាងនោះ ។ [៣]អ្នកណាមានសេចក្ដីសង្ឃឹមលើព្រះអង្គបែបនេះ អ្នកនោះបានជំរះខ្លួន
អោយបរិសុទ្ធ ដូចព្រះអង្គបរិសុទ្ធដែរ ។

[៤]អ្នកណាប្រព្រឹត្តអំពើបាប អ្នកនោះបំពានលើវិន័យ ដ្បិតអំពើបាបជាការបំពានលើវិន័
យ ។ [៥]អ្នករាល់គ្នាដឹងស្រាប់ហើយថា ព្រះយេស៊ូយាងមកដើម្បីដកបាបចេញពីមនុស្ស



ប. (ឈ្មោះ....) ចាប់ពីពេលនេះតទៅ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ជ្រួតជ្រាបក្នុងភាពទន់ខ្សោយរបស់អ្នកហើយ ។

ទាំងអស់គ្នា៖ សូមអរព្រះគុណព្រះអម្ចាស់ ។

ចូរតាំងចិត្តអធិដ្ឋានដោយស្ងៀមស្ងាត់ ។

# ៦ - ពិធីទទួលព្រះកាយព្រះគ្រីស្ត

ប. តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ និងតាមការប្រៀនប្រដៅរបស់ព្រះអង្គ យើងខ្ញុំហ៊ានទូលថា ៖

**ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !**

**សូមសម្ដែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ**

**សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់**

**សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី**

**ដូចនៅស្ថានបរមសុខដែរ។**

**សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។**

**សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក**

**ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។**

**សូមកុំបណ្ដោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។**

**តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច។**

លោកបូជាចារ្យយកប្រេងមកលាបថ្ងាសនិងដៃអ្នកជំងឺ ទាំងមានប្រសាសន៍ថា៖

ប. សូមព្រះអម្ចាស់អាណិតមេត្តាលើកទឹកចិត្ត..... (បង, តា, យាយ...) ដោយអានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។

ទាំងអស់គ្នា៖ អាម៉ែន ។

ប. សូមព្រះអម្ចាស់ទ្រង់ព្រះមេត្តាលើកលែងទោសទាំងអស់របស់... (បង, តា, យាយ...) សូមទ្រង់សង្គ្រោះ (បង, តា, យាយ...) និងប្រោសឲ្យបានជាសះស្បើយផង ។

ទាំងអស់គ្នា៖ អាម៉ែន ។

ប. សូមបងប្អូនតាំងចិត្តអធិដ្ឋាន

បពិត្រព្រះអម្ចាស់យេស៊ូគ្រិស្ត ជាព្រះសង្គ្រោះមនុស្សលោក ព្រះអង្គបានទទួលទុក្ខលំបាករបស់យើង នៅលើឈើឆ្កាង ។ យើងខ្ញុំសូមអង្វរព្រះអង្គសម្រាប់ .... ជាបងប្អូនយើងខ្ញុំ ដែលកំពុងរងគ្រោះដល់ជីវិត ។ ព្រះអង្គបានរំដោះគាត់ ហើយព្រះអង្គទើបនឹងប្រោសប្រណីគាត់ដោយប្រេងដ៏វិសុទ្ធ

សូមព្រះអង្គសម្រាលការឈឺចុកចាប់របស់គាត់ ទាំងលើកទឹកចិត្តគាត់ក្នុងពេលដ៏សែនវេទនានេះ

សូមព្រះអង្គប្រោសឲ្យគាត់មានសេចក្ដីសង្ឃឹមថា នឹងទទួលការសង្គ្រោះ ។ យើងខ្ញុំសូមអង្វរព្រះអង្គ ដែលមានព្រះជន្មគង់នៅអស់កល្បជាអង្វែងតរៀងទៅ ។ ទាំងអស់គ្នា៖ អាម៉ែន ។



លោក ដ្បិតគ្មានបាបនៅក្នុងព្រះអង្គទាល់តែសោះ ។ [6]អ្នកណាស្ថិតនៅជាប់ នឹងព្រះអង្គ អ្នកនោះមិនប្រព្រឹត្តអំពើបាបទេ រីឯអ្នកប្រព្រឹត្តអំពើបាប មិនដែលបានឃើញព្រះអង្គ ព្រមទាំងមិនស្គាល់ព្រះអង្គផង ។

ប. នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ គ្រ. សូមអរព្រះគុណព្រះជាម្ចាស់ ។

## ទំនុកតំកើងលេខ ១៣០(១២៩) បទពាក្យ ៧

១. បពិត្រព្រះជាអម្ចាស់អើយ ខ្ញុំស្រែកដង្ហើយរកព្រះអង្គ
ពីក្នុងរណ្ដៅជ្រៅកន្លង មេត្តាជួយផងផុតពីស្លាប់ ។
២. សំឡេងខ្ញុំឮដូចចំរៀង សូមព្រះអង្គផ្ទៀងព្រះកាណ៌ស្ដាប់
ពាក្យខ្ញុំអង្វរទទូចប្រាប់ រៀបរាប់រ៉ាយរ៉ាប់សូមសន្ដោស ។
៣. បពិត្រព្រះម្ចាស់ដ៏ឧត្ដម បើព្រះអង្គចាំពីកំហុស
អំពើបាបកម្មជនស្រីប្រុស គ្មានម្នាក់ណាសោះរួចខ្លួនឡើយ ។
៤. ប៉ុន្ដែព្រះអង្គតែងអត់ទោស ប្រណីសន្ដោសខ្ញុំធូរស្បើយ
រួចផុតទុក្ខទោសបានល្ហែល្ហើយ គឺព្រះអង្គហើយខ្ញុំគោរព ។
៥. ខ្ញុំទុកចិត្តលើព្រះអម្ចាស់ ជីវិតខ្ញុំនេះផ្ញើសព្វគ្រប់
សង្ឃឹមលើព្រះបន្ទូលគាប់ មិនឈរមិនឈប់ទេព្រះអង្គ ។
៦. ខ្ញុំទន្ទឹងចាំព្រះអម្ចាស់ ជាងអ្នកយាមផ្ទះទៅទៀតផង
ពេលឃើញថ្ងៃរះស្រស់បំព្រង រួចផុតទុក្ខផងមួយរាត្រី ។
៧. ឱ! អ៊ីស្រាអែលសូមទុកចិត្ត ព្រះល្អវិសុទ្ធដោយព្រះទ័យ
មេត្តាករុណាត្រាប្រណី ទ្រង់សព្វព្រះទ័យជួយជានិច្ច ។
៨. ព្រះអង្គរំដោះអ៊ីស្រាអែល ពីកំហុសដែលមានច្រើនតិច
គេបានប្រព្រឹត្តជាប់ជានិច្ច ព្រះអង្គសម្រេចបានសុខសាន្ដ ។

**រជ្ជុំវចម្មតា**

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

ឱ! ព្រះបិតាអើយ សូមឲ្យអស់អ្នកជឿលើទូលបង្គំ រួមគ្នាជាធ្លុងតែមួយ
ដើម្បីឲ្យមនុស្សលោកដឹងថាព្រះអង្គបានចាត់ទូលបង្គំឲ្យមកមែន ។

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

**រជ្ជុំវអប់រំពិសេស**

សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺនៃព្រះជាម្ចាស់
សូមកោតសរសើរព្រះអង្គ ។

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត
គំមិតយើងខ្ញុំ ដើម្បីទទួលព្រះសង្គ្រោះយើង ។

ប. ✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្តលូកា** ២៣, ៤២-៤៣

[៤២]«ឱព្រះបិតាអើយ! ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យ សូមដកយកពែងនៃទុក្ខលំបាក
នេះ ចេញឲ្យឆ្ងាយពីទូលបង្គំទៅ ។ ប៉ុន្តែ សូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំឡើយ គឺឲ្យ
សម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ» ។ [៤៣]ពេលនោះមានទេវទូតមួយរូប ចុះពី
ស្ថានបរមសុខមកឲ្យព្រះអង្គឃើញ ដើម្បីលើកទឹកចិត្តព្រះអង្គ ។

ប. នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

គ្រ. សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត ។



# ៤ - ពាក្យអង្វរ

- សូព្រះអម្ចាស់យាងមកថែរក្សា និងគាំទ្របងប្អូនយើងខ្ញុំនេះ ។

  ទាំងអស់គ្នា៖ **សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។**

- សូមព្រះអម្ចាស់រំដោះគេឲ្យរួចពីអំពើបាប និងពីការល្បួងរបស់មារ ។

  ទាំងអស់គ្នា៖ **សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។**

- សូមព្រះអម្ចាស់ប្រោសអោយគេបានធូរស្បើយ ។

  ទាំងអស់គ្នា៖ **សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។**

- សូមព្រះអម្ចាស់ប្រោសប្រទានជីវិតដ៏ពេញលេញ
  អោយបងប្អូនយើងខ្ញុំនេះផង ។

  ទាំងអស់គ្នា៖ **សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ ។**

# ៥ - ការដាក់ដៃ និង ពិធីលាបប្រេង

ប. បពិត្រព្រះបិតាជាអម្ចាស់ប្រកបដោយធម៌មេត្តាករុណាយ៉ាងក្រៃលែង! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ព្រោះព្រះអង្គតែងអាណិតអាសូរអ្នកជំងឺ ។ សូមទ្រង់ព្រះមេត្តាប្រោសប្រណីដល់បងប្អូនយើងខ្ញុំ ដែលយើងនឹងលាបប្រេងនៅពេលឥឡូវនេះ ។ សូមលើកទឹកចិត្តគាត់ នៅពេលគាត់កើតទុក្ខលំបាក សូមឲ្យគាត់មានជំនឿកាន់តែមាំមួនឡើង និងមានចិត្តសង្ឃឹមផង ។ យើងខ្ញុំសូមអង្វរព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គនិងជាអម្ចាស់យើងខ្ញុំ ។ គ្រ. អាមែន ។